01070138

E341

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 02 / 2015
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ជូនចំពោះ៖** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីណែនាំដល់គ្រប់ភាគីទាំងអស់ស្តីអំពីការប្រើប្រាស់ប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ

1. អង្គជំនុំជម្រះបានទទួលសំណើជាច្រើនសុំឱ្យមានការបញ្ជាក់បំភ្លឺពីបែបបទអនុវត្តចំពោះការប្រើប្រាស់ប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ (Interface) (សូមមើល ប្រតិចារឹក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ទំព័រ ៥៤-៥៨ (ភាសាអង់គ្លេស))។ ផ្អែកទៅលើការអនុវត្តក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបញ្ជាក់ឡើងវិញពីគោលការណ៍ណែនាំដូចខាងក្រោមនេះ ដើម្បីធានាថា ប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ នៅតែជាឧបករណ៍ដ៏សំខាន់ក្នុងការធានានូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័សនៅក្នុងសំណុំរឿង ០០២/០២ នេះ និងជាពិសេស ដើម្បីធានាថា ការពិភាក្សាដេញដោលគោរពនូវគោលការណ៍ចំពោះមុខបានពេញលេញ។

2. មុនពេលចាប់ផ្តើមសវនាការពិនិត្យភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់អង្គភាពបណ្ណសារឱ្យបង្កើតប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ ដើម្បីអនុញ្ញាត

ឲ្យមានការជូនដំណឹងជាមុនអំពីឯកសារដែលភាគីមានបំណងយកមកប្រើប្រាស់ក្នុងអំឡុងពេលសួរដេញ-ដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញជាក់លាក់ណាមួយ។ ប្រព័ន្ធនេះក៏ជាវិធីងាយស្រួលផងដែរក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះ ភាគីទាំងអស់ និងអ្នកបកប្រែផ្ទាល់មាត់ អំពីឯកសារដែលមានច្រើនទំព័រ និង លេខ ERN ។ ដូច្នេះហើយ ប្រព័ន្ធនេះមានតួនាទីជួយសម្រួលឲ្យកិច្ចដំណើរការនីតិវិធីសវនាការប្រព្រឹត្តទៅបានល្អ (សូមមើល ប្រតិចារឹក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ១០១-១០២ (ជាភាសាអង់គ្លេស))។ ដោយសារវិសាលភាពនៃសំណុំរឿងមានទំហំធំនោះ ប្រសិនបើភាគីជារឿយៗស្នើសុំដាក់បង្ហាញភ័ស្តុតាង ដោយមិនមានការជូនដំណឹងតាមរយៈប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃទេ វានឹងនាំឲ្យមានការពន្យារពេលកិច្ចដំណើរការនីតិវិធី បង្កើតនូវភាពច្របូកច្របល់ និងប៉ះពាល់ដល់លក្ខខណ្ឌតម្រូវចំពោះការពិភាក្សាដេញដោលតទល់គ្នា។ បន្ថែមទៅលើសារៈសំខាន់នៃប្រព័ន្ធផ្ទុកឯកសារដូចដែលបានគូសបញ្ជាក់ខាងលើ អង្គជំនុំជម្រះបានកត់សម្គាល់ដោយក្តីបារម្ភថា ភាគីមួយចំនួនបានដកស្រង់ផ្នែក ឬ ឃ្លាប្រយោគនៃឯកសារមួយចំនួនដោយច្បោលៗ ហើយការធ្វើដូច្នេះអាចនាំឲ្យមានការភ័ន្តច្រឡំដល់បុគ្គលទាំងឡាយដែលកំពុងផ្តល់សក្ខីកម្ម។

3. ការប្រើប្រាស់ប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃនេះ គឺជាលក្ខខណ្ឌតម្រូវមួយ ហើយភាគីទាំងអស់ត្រូវដាក់ឯកសារទាំងឡាយដែលខ្លួនមានបំណងប្រើប្រាស់សម្រាប់ដេញដោលសាក្សី ដើម-បណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញ ឲ្យបានមុនពេលថ្ងៃត្រង់នៃថ្ងៃធ្វើការ មួយថ្ងៃមុនពេលការផ្តល់សក្ខីកម្មចាប់ផ្តើម (សូមមើល ឯកសារ E218 កថាខណ្ឌ ២៣; ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ២៤-២៦ (ជាភាសាអង់គ្លេស))។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា លទ្ធភាពក្នុងការប្រមើលមើលដឹងជាមុននូវគ្រប់សេណារីយ៉ូដែលអាចនឹងកើតមានឡើង មុនពេលការចោទសួរបុគ្គលណាម្នាក់នោះមានការលំបាក ហេតុដូច្នេះហើយ ចាំបាច់ត្រូវមានភាពបត់បែនមួយចំនួននៅក្នុងការដាក់ចេញនូវលក្ខខណ្ឌតម្រូវនេះ (សូមមើលប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣៨-៤០ (ជាភាសា អង់គ្លេស); ប្រតិចារឹក ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ៩-១០ (ជាភាសាអង់គ្លេស))។

4. អង្គជំនុំជម្រះបញ្ជាក់ថា ក្នុងករណីពិសេស ប្រសិនបើភាគីណាមួយមានបំណងប្រើប្រាស់ឯកសារដែលមិនបានជូនដំណឹងឲ្យបានទាន់ពេលវេលានៅលើប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃទេនោះ ភាគីនោះប្រើប្រាស់ឯកសារនោះបាន តែក្នុងករណីដែលមានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះប៉ុណ្ណោះ។ ប្រសិនបើករណីនេះកើតឡើងនោះ ភាគីត្រូវជូនដំណឹងដល់អង្គជំនុំជម្រះថា ខ្លួនមានបំណងប្រើប្រាស់ឯកសារដែលពុំមាននៅលើប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ និងពន្យល់ថា ហេតុអ្វីបានជាកាលៈទេសៈដែលមិនអាចព្យាករណ៍ជាមុនតម្រូវឲ្យប្រើប្រាស់ឯកសារដែលស្នើសុំនេះ។ ភាគីដទៃទៀតនឹង

មានឱកាសឆ្លើយតបទៅនឹងសំណើសុំនេះ មុនពេលអង្គជំនុំជម្រះសម្រេចទៅលើការអនុញ្ញាត ឬមិនអនុ-ញ្ញាតឱ្យប្រើប្រាស់ឯកសារនោះ។ ដំណោះស្រាយទៅលើការខកខានខាងលើ អាចរួមមាន ការផ្តល់ពេលវេលាទៅឱ្យភាគីដទៃទៀតដើម្បីពិនិត្យមើលទៅលើឯកសារទាំងនោះ ដែលមិនមាននៅក្នុងប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ និងកាត់បន្ថយពេលវេលាដែលត្រូវផ្តល់ទៅឱ្យភាគីស្នើសុំ។ នីតិវិធីនេះនឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះរក្សាបាននូវតុល្យភាព រវាងលក្ខខណ្ឌតម្រូវនៃការជូនដំណឹងជាមុន និងភាពចាំបាច់ក្នុងការសម្របទៅតាមតម្រូវការនៃការជំនុំជម្រះ។

5. អង្គជំនុំជម្រះរម្លឹកទៀតថា គោលបំណងនៃប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃនេះនឹងបរាជ័យទាំងស្រុង ប្រសិនបើភាគីដាក់បញ្ចូលឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្នុងប្រព័ន្ធដាក់ឯកសារដែលហួសពីលទ្ធភាពសម្រាប់យកមកដេញដោលបុគ្គលណាម្នាក់នៅក្នុងពេលសវនាការប្រចាំថ្ងៃជាក់លាក់នីមួយៗ (សូមមើល ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣៤ (ជាភាសាអង់គ្លេស))។ ឯកសារនានាដែលនឹងដាក់នៅក្នុងប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃ គួរតែត្រូវបានកំណត់ដោយសមស្របត្រឹមតែឯកសារទាំងឡាយណាដែលភាគីរំពឹងថានឹងយកមកប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកជំនាញប៉ុណ្ណោះ។ ចំនួនឯកសារដែលសមស្របនោះអាស្រ័យទៅលើរយៈពេលនៃការផ្តល់សក្ខីកម្មរបស់បុគ្គល ចំនួននៃកិច្ចសម្ភាសដែលបានធ្វើ ឬ សំណេរនានារបស់បុគ្គលនោះ និង កត្តាផ្សេងៗទៀត។ ប្រសិនបើភាគីខកខានមិនបានប្រតិបត្តិតាមការអនុវត្តនេះដោយសុចរិតទេនោះ អង្គជំនុំជម្រះអាចនឹងបង្កើនរយៈពេលនៃការជូនដំណឹងដែលបានតម្រូវ ដើម្បីឱ្យសមាមាត្រទៅទៅនឹងចំនួនឯកសារដែលដាក់។

6. ជាចុងក្រោយ អង្គជំនុំជម្រះរម្លឹកដល់ភាគីទាំងអស់ថា ប្រព័ន្ធដាក់ឯកសារសម្រាប់សវនាការប្រចាំថ្ងៃនេះ មិនមែនជាយន្តការមួយដើម្បីផ្តល់ការជូនដំណឹងអំពីឯកសារថ្មីៗឡើយ ដោយឯកសារថ្មីនោះអាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន ក្រោយពេលអង្គជំនុំជម្រះទទួលយកសំណើសុំដាក់ឯកសារដែលបានគោរពតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងតែប៉ុណ្ណោះ (សូមមើល ឯកសារ E218 កថាខណ្ឌ ២៣)។ អង្គជំនុំជម្រះរម្លឹកបន្ថែមទៀតដល់ភាគីទាំងអស់ថា វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង នៅតែអនុវត្តសម្រាប់ឯកសារទាំងអស់ដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។